ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និងឈ្មោះសំណុំរឿង : ២៨/០៩-យ៉ាក ជីន**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **ឈឺវ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **វ៉ែន តៅ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **គង់ ផល្លះ**

**ភាគីនៃវិវាទ**

១- **ភាគីនិយោជក**

ឈ្មោះ : **យ៉ាកជីន (ខេមបូឌា) អ៊ីុន**

អាសយដ្ឋាន : ភូមិតាសេក ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ : ០១២ ៩៧០ ២៨៩ លេខទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក យូ បូរ៉ា ប្រធានរដ្ឋបាល

២- លោកស្រី នូ ផាន់ដា ជំនួយការរដ្ឋបាល

២- **ភាគីកម្មករនិយោជិត**

**ឈ្មោះ : សហព័ន្ធសហជីព-សហជីព យុវជនខ្មែរ នៃរោងចក្រកាត់ដេរ យ៉ាកជីន**

អាសយដ្ឋាន : ភូមិតាសេក ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល

លេខទូរស័ព្ទ : ០១២ ៩០៧ ៩០២ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត: គ្មាន



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

## បញ្ហាក្ដីវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ចំពោះកម្មករធ្វើការបន្ថែមម៉ោង សូមឱ្យស្ថិតនៅលើគោលការណ៍ស្ម័គ្រចិត្ត ដោយគ្មានការបង្ខិតបង្ខំ រឺចាត់វិធានការអ្វីមកលើកម្មករឡើយ ។ ក្រុមហ៊ុនមិនឯកភាព ។

២- នៅពេលក្រុមហ៊ុនបើកប្រាក់ឈ្នួលជូនកម្មករប្រចាំខែ សុំឱ្យគិត ឱ្យបានច្បាស់លាស់ ។ ក្រុមហ៊ុនមិនឯកភាព ។

៣- សុំក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ ២ ដុល្លារ បន្ថែម ពោលគឺ ៧ ដុល្លារ ក្នុងមួយខែ ។ ក្រុមហ៊ុនមិនឯកភាព ។

៤- សុំឱ្យក្រុមហ៊ុនរៀបចំការបើកប្រាក់ជូសការឈប់សម្រាកប្រចាំឆ្នាំ ឱ្យបានពីរដងក្នុងមួយឆ្នាំ ពោលគឺពេលចូលឆ្នាំខ្មែរ និងបុណ្យភ្ជុំបិណ្ឌ ។ ក្រុមហ៊ុនមិនឯកភាព ។

៥- សុំឱ្យក្រុមហ៊ុនកែសម្រួលការងារទារកដ្ឋាន ដែលមានស្រាប់ឱ្យបានល្អឡើងវិញ ។ ក្រុមហ៊ុនមិនឯកភាព ។

៦- សុំឱ្យក្រុមហ៊ុនអនុញ្ញាតស្ត្រីមានផ្ទៃពោះទៅពិនិត្យសុខភាពក្នុងមួយខែ មួយថ្ងៃ ដោយរក្សាប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំនៅដដែល ។ ក្រុមហ៊ុនមិនឯកភាព ។

៧- សុំឱ្យក្រុមហ៊ុនរៀបចំបន្ទប់ទឹកឱ្យបានស្អាត ព្រមទាំងទឹកប្រើប្រាស់ និងទឹកហូបឱ្យបានគ្រប់គ្រាន់ និងមានអនាម័យ ។ ក្រុមហ៊ុនមិនឯកភាព ។

៨- សុំឱ្យក្រុមហ៊ុនណែនាំថ្នាក់ដឹកនាំក្រុម ស៊ុបភើវ៉ាយស៊ើរ គ្រប់ក្រុម គ្រប់ផ្នែក ឱ្យមានចរិតសមរម្យ ។ ក្រុមហ៊ុនមិនឯកភាព ។

៩- សុំឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួលគោលជូនកម្មករទូទៅ ដោយអនុវត្តតាមគោលការណ៍ ដែលធ្លាប់អនុវត្តកន្លងមក ។ ក្រុមហ៊ុនមិនឯកភាព ។

១០- សុំឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលពីកម្មករ ដែលជាសមាជិកសហព័ន្ធសហជីពយុវជនខ្មែរ ម្នាក់ ១០០០ រៀល (មួយពាន់រៀល) ជូនសហជីពយុជនខ្មែរ ។ ក្រុមហ៊ុនមិនឯកភាព ។

១១- សុំឱ្យក្រុមហ៊ុនផ្តល់ ៥ ដុល្លារ ក្នុងមួយខែ ជូនកម្មករ សម្រាប់ថ្លៃការស្នាក់នៅ រឺ សោហ៊ុយធ្វើដំណើរក្នុងមួយខែ ។ ក្រុមហ៊ុនមិនឯកភាព ។

១២- សុំឱ្យក្រុមហ៊ុនបើកទ្វារអគារផលិតកម្មពេលថ្ងៃត្រង់ ឱ្យកន្លះម៉ោងមុន ដូចធ្លាប់អនុវត្តកន្លងមក ។ ក្រុមហ៊ុនមិនឯកភាព ។

១៣- សុំឱ្យក្រុមហ៊ុនបើកប្រាក់រង្វាន់ប្រចាំសប្តាហ៍ និងប្រាក់រង្វាន់ធ្វើការទៀងទាត់ប្រចាំសប្តាហ៍ ។ ក្រុមហ៊ុនមិនឯកភាព ។

១៤- សុំឱ្យក្រុមហ៊ុនអនុវត្តថ្ងៃឈប់សម្រាកពិសេសចំនួន ៧ ថ្ងៃ បន្ថែមពីលើ ថ្ងៃជួសការឈប់សម្រាកប្រចាំឆ្នាំចំនួន ១៨ ថ្ងៃ ជូនកម្មករ ដោយរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ ព្រមទាំងប្រាក់បន្ទាប់បន្សំនៅដដែល។ ក្រុមហ៊ុនមិនឯកភាព។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាស ស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ០៨២/០៩ ក.ប./កណ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩។

## សវនាការ និង សន្ទេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៩ (វេលាម៉ោង ០២:០០ នាទី រសៀល)។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានទទួលបណ្តឹងរបស់សហព័ន្ធសហជីពយុវជនខ្មែរ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទាមទារឱ្យកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ ប៉ុន្តែពុំបានទទួលលទ្ធផលសះជាទេលើការទាមទារចំនួន ១៤ ចំណុច។ ចំណុចមិនសះជាចំនួន ១៤ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន១៤ចំណុចនេះ នៅថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៩ (វេលាម៉ោង ០២:០០ នាទី រសៀល) ។ ប៉ុន្តែ ភាគីកម្មករនិយោជិតអវត្តមានដោយគ្មានមូលហេតុ ចំណែកឯភាគីនិយោជកវិញបានអញ្ជើញមកចូលរួមតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ហេតុនេះហើយ នៅក្នុងរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក : គ្មាន**

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន យ៉ាកជីន (ខេមបូឌា)អ៊ីន លេខ ០៨២ កប/កណ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៩។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន យ៉ាកជីន (ខេមបូឌា) អ៊ីន ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១២៥ កប/អក/វក/លកអ. ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៩។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១២៤ កប/អក/វក/លកអ. ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៩។

៣- កំណត់ហេតុ ស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាល ពីបញ្ជីឈ្មោះអាជ្ញាកណ្តាលស្នើដោយសហជីព កម្មករនិយោជិត ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម

**ការរកឃើញអង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមិនអាចរកឃើញអង្គហេតុ ទាក់ទងនឹងការទាមទារទាំងនេះទេ ដោយហេតុថា ភាគីកម្មករនិយោជិត អវត្តមាននៅក្នុងថ្ងៃសវនាការ ដោយមិនបានផ្ដល់មូលហេតុណាមួយឡើយ ។

**ហេតុផលក្នុងការធ្វើសេចក្ដីសម្រេច**

តាមប្រការ ២១ នៃប្រកាស ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល លេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ *" ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្ដាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្ដាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្ដាលដោយចេញជាសេចក្ដីបង្គាប់ "* ។

បន្ថែមពីនេះទៀត វិធាន ៤.៧ នៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅក្នុងឧបសម្ព័ន្ធនៃប្រកាស ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល លេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *" ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាង ក្នុងដំណើរការអាជ្ញាកណ្ដាល ក្រុមអាជ្ញាកណ្ដាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្ដាល ដោយចេញជាសេចក្ដីបង្គាប់ ។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្ដាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្ដាល មុនពេលធ្វើសេចក្ដីសម្រេចរបស់ខ្លួន "* ។

ផ្អែកលើប្រការ ២១ និង វិធាន ៤.៧ ខាងលើនេះ នៅក្នុងសេចក្ដីបង្គាប់លេខ ៣០/០៥-មូរៀ. លេខ ១៦/០៧-ឡូទូសតី លេខ ២៧/០៧-អ៊ីម និង វ៉ៃ ៣ លេខ ៩៥/០៨-យ៉ុង វ៉ា ទី១ លេខ ១៣២/០៨-ជី អេច ជី លេខ ១៣៨/០៨-ម៉ាលើន និងលេខ ១៩១/០៨-វិល ស៊ិន. លេខ ០៩/០៩-នីមបឹស ថិចថាយ៍ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា មានលក្ខខណ្ឌបី ដែលត្រូវបំពេញមុនពេលដែលក្រុមប្រឹក្សាអាជ្ញាកណ្ដាលអាចបញ្ចប់ដំណើរការអាជ្ញាកណ្ដាល ដោយចេញជាសេចក្ដីបង្គាប់បាន ។ លក្ខខណ្ឌទី១ គឺ ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ ។ លក្ខខណ្ឌទី២ គឺ ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ គឺ ភាគីមិនបានផ្ដល់មូលហេតុ សម្រាប់ការមិនបង្ហាញខ្លួន ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល និងពិចារណាថា តើលក្ខខណ្ឌទាំងបីត្រូវបានបំពេញដែរឬអត់?

**លក្ខខណ្ឌទី ១ : ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ**

ដូចដែលបានបញ្ជាក់ក្នុងវិធាន ៤.៧ ខាងលើ ក្រុមអាជ្ញាកណ្ដាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្ដាលដោយចេញជាសេចក្ដីបង្គាប់ ប្រសិនបើភាគីណាមួយមិនបាន

បង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្ដាល ក្នុងករណីដែលភាគីវិវាទត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរអាជ្ញាកណ្ដាល ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានរកឃើញថា លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានធ្វើលិខិតអញ្ជើញជាផ្លូវការទៅកាន់ភាគីទាំងពីរ ។ លិខិតអញ្ជើញទាំងនេះ ត្រូវបានធ្វើឡើងដោយនីតិវិធីជាប្រចាំរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានទំនាក់ទំនង ទៅកាន់ភាគី អំពីកាលបរិច្ឆេទ ពេលវេលា និង ទីកន្លែងនៃថ្ងៃសវនាការតាមរយៈលិខិតអញ្ជើញជាលាយលក្ខណ៍អក្សរ និងតាមទូរស័ព្ទ ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល យល់ឃើញថាលក្ខខណ្ឌទី១ ត្រូវបានបំពេញ ។

**លក្ខខណ្ឌទី២: ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ**

ប្រការ ១៩ នៃប្រកាសស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល លេខ០ ៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្ដាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬ តំណាងដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ ។"*

បន្ថែមពីនេះទៀត ប្រការ២០ នៃប្រកាសស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល លេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ក៏បានចែងថា *"ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្ដាល ..... ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្ដាលបានអញ្ជើញអោយចូលរួម ។"*

នៅក្នុងករណីនេះ ភាគីកម្មករនិយោជិត មិនបានចូលរួមសវនាការហើយក៏មិនបានចាត់ឱ្យមានអ្នកតំណាង (ដូចជា ខាងសហព័ន្ធសហជីព ឬ មេធាវី) ដើម្បីតំណាងពួកគេនៅក្នុងសវនាការនោះទេ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា លក្ខខណ្ឌ ទី២ ក៏ត្រូវបានបំពេញដែរ ។

**លក្ខខណ្ឌទី៣: ភាគីមិនបានផ្ដល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

ដូចដែលបានបញ្ជាក់ក្នុងប្រការ ២១ នៃប្រកាសខាងលើ ក្រុមអាជ្ញាកណ្ដាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្ដាលដោយចេញជាសេចក្ដីបង្គាប់ ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្ដាលដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ។ ក្នុងករណីនេះក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ភាគីកម្មករនិយោជិតអវត្តមាន និងមិនបានផ្ដល់មូលហេតុត្រឹមត្រូវអ្វីទាំងអស់ដល់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលអំពីការមិនចូលរួមសវនាការនោះទេ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា លក្ខខណ្ឌ ទី៣ ក៏ត្រូវបានបំពេញដែរ ។

6

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បិទសំណុំរឿងលេខ ២៨/០៩-យ៉ាក ជីន នេះ ដោយភាគីកម្មករនិយោជិត មិនមានវត្តមាននៅពេលសវនាការ។

ដោយសំអាងលើអង្គហេតុ ភស្តុតាង និង អង្គច្បាប់ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ:

## សម្រេច និង បង្គាប់

បិទសំណុំរឿងលេខ ២៨/០៩- យ៉ាក ជីន។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **ឈឹម តិរម្យ**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **ម៉ែន ពៅ**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: ------------------------------